# សហគមន៍យើងរីកចម្រើន

## ចាប់ផ្តើមពីអ្នក



# សៀវភៅជំនួយស្មារតី

## សម្រាប់គណៈកម្មការកៀរគរសហគមន៍

## ផលិតដោយ:

មជ្ឈមណ្ឌលភ្នំពេញ ជាន់ទី៣ កែងផ្លូវព្រះស៊ីហនុ (២៧៤) និង មហាវិថីព្រះសុធារស
សង្កាត់ទន្លេបាសាក់ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ១៤៩ ប្រៃសណីយ៍ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (៨៥៥-២៣) ២១៧ ៨៥៥
ទូរសារ (៨៥៥-២៣) ២១៧ ៨៥៦
www.pactcambodia.org

## ឧបត្ថម្ភដោយ:

*ការបោះពុម្ពផ្សាយនេះ អាចដំណើរការទៅបាន ដោយសារជំនួយសប្បុរសធម៌របស់ប្រជាពលរដ្ឋអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ ។ រាល់គំនិតដែលបានបញ្ចេញនៅក្នុងឯកសារនេះ ជាការទទួលខុសត្រូវរបស់អង្គការផេកកម្ពុជា ហើយមិនឆ្លុះបញ្ចាំងទស្សនៈរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ ឬ រដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ ។*

**សហគមន៍យើងរីកចម្រើន  ចាប់ផ្តើមពីអ្នក**

**សៀវភៅជំនួយស្មារតី  សម្រាប់គណៈកម្មការគ្រប់គ្រងសហគមន៍**

*បោះពុម្ពលើកទី ១*

*ខែ ធ្នូ ឆ្នាំ ២០០៩*

# មាតិកា

ទំព័រ


សេចក្តីផ្តើម

តើសៀវភៅជំនួយស្មារតីនេះបង្កើតឡើងសម្រាប់នរណា? ១

តើគណៈកម្មការកៀរគរសហគមន៍ជាអ្វី? ១

តើនរណាខ្លះអាចក្លាយជាសមាជិកគណៈកម្មការកៀរគរសហគមន៍? ២

តើសមាជិកគណៈកម្មការកៀរគរសហគមន៍នឹងទទួលបាន អត្ថប្រយោជន៍អ្វីខ្លះ? ៣

តើសមាជិកគណៈកម្មការកៀរគរសហគមន៍ចូលរួមធ្វើអ្វីខ្លះ? ៤

តើសមាជិកគណៈកម្មការកៀរគរសហគមន៍នឹងទទួលចំណេះដឹងអ្វីខ្លះ? ១៤

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ដែលបានផ្តល់ថវិកាសម្រាប់ការបោះពុម្ពសៀវភៅជំនួយស្មារតីសម្រាប់គណៈកម្មការកៀរគរសហគមន៍ (គ.ក.ស) ។ សូមថ្លែងអំណរគុណថ្នាក់ដឹកនាំ អង្គការផេកកម្ពុជា មន្ត្រីជំនាញរបស់កម្មវិធីល្អ បុគ្គលិកអង្គការផេកកម្ពុជា ព្រមទាំងបុគ្គលិកអង្គការដៃគូទាំងអស់ ដែលបានរួមចំណែកក្នុងការបង្កើតសៀវភៅនេះឡើង។

សូមថ្លែងអំណរគុណដល់តំណាងក្រុមប្រឹក្សាឃុំសង្កាត់ តំណាងសមាជិកគណៈកម្មការកៀរគរសហគមន៍ទាំងអស់ ដែលបានចូលរួមចំណែកក្នុងការផ្តល់យោបល់កែលម្អ និងធ្វើឲ្យសៀវភៅជំនួយស្មារតីនេះ កាន់តែមានអត្ថន័យពេញលេញសម្រាប់ជាជំនួយជំនួយស្មារតីដល់សមាជិកគ.ក.ស ក្នុងការបំពេញកិច្ចការរបស់ខ្លួនឲ្យមានប្រសិទ្ធិភាព និងឆ្លើយទៅនឹងសេចក្តីរំពឹងទុករបស់ប្រជាពលរដ្ឋ ។

# សេចក្តីផ្តើម:

កម្មវិធីគាំទ្រកំណែទម្រង់រដ្ឋបាលមូលដ្ឋាន ហៅកាត់ថា (លួ) ជាកម្មវិធីមួយក្នុងចំណោមកម្មវិធីនានា របស់អង្គការផេកកម្ពុជា ដែលបានទទួលការគាំទ្រថវិកាពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ។ កម្មវិធីលួ បានផ្តល់នូវការកសាង សមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ចំនួន ៣៥៦ ឃុំ ក្នុងខេត្តចំនួន ៨ គឺ ខេត្តបាត់ដំបង ពោធិ៍សាត់ កណ្តាល តាកែវ ស្វាយរៀង ព្រៃវែង កំពង់ចាម និង ខេត្តកំពង់ធំ ។ កម្មវិធីលួ មានគោលដៅដើម្បីលើកកម្ពស់ការផ្សារភ្ជាប់ទំនាក់ទំនងប្រកបដោយនិរន្តរភាព និងសកម្មចូលរួមរវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋ ។ ដើម្បីចូលរួមចំណែកសំរេចបាននូវគោលដៅនេះ កម្មវិធីលួ បានចូលរួមគាំទ្រសហគមន៍បង្កើតគណ:កម្មការមួយដើម្បីដើរតួនាទីជាអ្នកកសាងស្ពានទំនាក់ទំនងរវាងប្រជាពលរដ្ឋ (ម្ចាស់ឆ្នោត) និងក្រុមប្រឹក្សាឃុំ សង្កាត់។

គណ:កម្មការនេះមានឈ្មោះថា គណ:កម្មការកៀរគរសហគមន៍ ហៅកាត់ "គ.ក.ស" បានបង្កើតឡើងដោយការបោះឆ្នោត និងជ្រើសរើសផ្ទាល់ពីប្រជាពលរដ្ឋក្នុងមូលដ្ឋានតាមលក្ខណ:ប្រជាធិបតេយ្យ និងមានការទទួលស្គាល់ពីក្រុមប្រឹក្សាឃុំ សង្កាត់ ។ គ.ក.ស ទទួលបានការពង្រឹងសមត្ថភាពពីបុគ្គលិកអង្គការដៃគូ របស់កម្មវិធីលួ តាមរយ:ការបណ្តុះបណ្តាល និងការបង្ហាត់បង្ហាញជាប្រចាំផងដែរ។

ដើម្បីជាជំនួយដល់ការពង្រឹងសមត្ថភាពរបស់ គ.ក.ស កម្មវិធីលួ បានបង្កើតសៀវភៅជំនួយស្មារតីនេះឡើងក្នុងគោលបំណង:

១- បង្ហាញពីសកម្មភាពចូលរួមរបស់ គ.ក.ស ឲ្យកាន់តែច្បាស់នៅក្នុងការកៀរគរការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន

២- បង្ហាញពីភាពងាយស្រួលដែល គ.ក.ស អាចអនុវត្តក្នុងការផ្សារភ្ជាប់ទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងក្រុមប្រឹក្សា ឃុំ សង្កាត់

៣- ជាឯកសារយោងសំរាប់អង្គការ និងសមាគមនានា ដើម្បីសិក្សាស្វែងយល់ពីកិច្ចការរបស់ គ.ក.ស ក្នុងការលើកកំពស់អភិបាលកិច្ចមូលដ្ឋាន។

## ១- តើសៀវភៅជំនួយស្មារតីនេះ បង្កើតឡើងសំរាប់នរណា?

សៀវភៅនេះ បង្កើតឡើងដើម្បីជាឯកសារបន្ថែម សម្រាប់ជំនួយស្មារតីដល់ សមាជិក គ.ក.ស អង្គការសហគមន៍មូលដ្ឋាន ប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ និងបុគ្គលិកអង្គការដៃគូកម្មវិធីល្អ ។

វាក៏អាចជាប្រយោជន៍ផងដែរ សម្រាប់អង្គការ និងស្ថាប័ននានា ដែលកំពុងធ្វើការក្នុងវិស័យអភិបាលកិច្ចមូលដ្ឋាន ព្រោះថា វាបានបង្ហាញឲ្យឃើញយ៉ាងច្បាស់ពីការស្ម័គ្រចិត្តលះបង់ពេវេលាជាប្រជាពលរដ្ឋគំរូរបស់ គ.ក.ស ក្នុងការចូលរួមយ៉ាងសកម្ម ដើម្បីជំរុញឲ្យប្រជាពលរដ្ឋចូលរួមសំដែងមតិយោបល់ ក្តីព្រួយបារម្ភ បញ្ហា តម្រូវការ និងចូលរួមជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីបង្កើនការយកចិត្តទុកដាក់ ក្នុងឆ្លើយតបទៅនឹងក្តីបារម្ភទាំងនោះប្រកបដោយការទទួលខុសត្រូវខ្ពស់ ។

ជាងនេះទៅទៀត សៀវភៅជំនួយស្មារតីនេះ នឹងផ្តល់នូវគោលគំនិតសំខាន់ៗដល់សមាជិក គ.ក.ស ឲ្យមើលឃើញកាន់តែច្បាស់ពីការរួមចំណែកដ៏ធំធេងរបស់ខ្លួន ក្នុងការជួយបំពេញបន្ថែម និងគាំទ្រដល់ការអនុវត្តន៍ការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក៏ដូចជារបស់ប្រជាពលរដ្ឋ ដើម្បីជម្រុញឲ្យមានការចូលរួមក្នុងដំណើរការអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួនប្រកបដោយនិរន្តរភាព សំដៅកាត់បន្ថយភាពក្រីក្រនៅជនបទ។

## ២- តើគណៈកម្មការកៀរគរសហគមន៍ជាអ្វី?

គណៈកម្មការកៀរគរសហគមន៍ គឺជាប្រជាពលរដ្ឋស្ម័គ្រចិត្តមួយក្រុម ដែលបានផ្តល់ការទុកចិត្តតាមរយៈការបោះឆ្នោតរបស់ប្រជាពលរដ្ឋមូលដ្ឋាន ដើម្បីធ្វើជាតំណាងរបស់ខ្លួនក្នុងការសម្របសម្រួលឲ្យមានជំនួបរវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋ ។ គ.ក.ស គឺជាតួអង្គដ៏សំខាន់ ក្នុងការសម្របសម្រួលឲ្យមានការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍន៍មូលដ្ឋាន ការអនុវត្តន៍គម្រោងឃុំ សង្កាត់ និងជួយផ្តល់ជាគំនិតយោបល់ដើម្បីស្ថាបនាដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ពីដំណើរការទាំងនោះ។

# ៣- តើនរណាខ្លះដែលអាចក្លាយជាសមាជិក គ.ក.ស?

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទចាប់ពីអាយុ ១៨ឆ្នាំ ឡើងអាចជា សិស្ស និស្សិត កសិករ កម្មករ មន្ត្រីរាជការចូលនិវត្តន៍ អ្នកផ្តុកមេរោគអេដស៍ (លើកលែងតែសកម្មជនគណបក្សនយោបាយ) មានទីលំនៅអចិន្ត្រៃយ៍នៅក្នុងភូមិដែលកំពុងរស់នៅ ហើយអាចលះបង់ពេលវេលា មានទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ អាជ្ញាធរមូលដ្ឋាន និងមានស្មារតីទឹកចិត្តចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍មូលដ្ឋាន ។ ជាងនេះទៀត បងប្អូនខ្មែរឥស្លាម និងជនជាតិដើមភាគតិច ក៏អាចក្លាយជាសមាជិក គ.ក.ស បានដែរ ឲ្យតែពួកគាត់ស្ម័គ្រចិត្តលះបង់ពេលវេលាខ្លះៗ សម្រាប់ចូលរួមចំណែកបំពេញតួនាទីជា គ.ក.ស ។



# ៤- តើសមាជិកគ.ក.សនឹងទទួលបានអត្ថប្រយោជន៍អ្វីខ្លះ?

នៅពេលដែលអ្នកភូមិនិយាយពីអត្ថប្រយោជន៍ គេសំដៅទៅដល់អត្ថប្រយោជន៍ជារូបីយ៍ និងអត្ថប្រយោជន៍អរូបីយ៍ ។ អត្ថប្រយោជន៍រូបីយ៍មានដូចជា: លុយកាក់ និងសម្ភារ:ផ្សេងៗ ដែលអាចមើលឃើញ កាន់បាន និងអាចប្រើប្រាស់បាន ។ ចំពោះសមាជិក គ.ក.ស ដែលធ្វើការក្នុងនាមជាអ្នកស្ម័គ្រចិត្ត អ្វីដែលពួកគាត់ទទួលបាននោះ គឺអត្ថប្រយោជន៍អរូបីយ៍វិញដូចជា ចំណេះដឹង បទពិសោធន៍ និងការគោរពស្រលាញ់ពីសំណាក់ប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន ដែលរស់នៅក្នុងសហគមន៍ផ្ទាល់របស់ពួកគាត់ ។ អត្ថប្រយោជន៍ទាំងនេះ គឺកើតចេញពីស្នាដៃ និងសមិទ្ធផលដែលជាពលិកម្មផ្ទាល់របស់ពួកគាត់ ក្នុងការរួមចំណែកជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងបងប្អូនប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍន៍សហគមន៍របស់ខ្លួន។



# ៥- តើសមាជិក គ.ក.ស ចូលរួមធ្វើអ្វីខ្លះ?

- កិច្ចការសំខាន់ៗរបស់ គ.ក.ស គឺចូលរួមផ្សព្វផ្សាយព័ត៌មានពីការរីកចំរើន ផែនការអភិវឌ្ឍន៍ គម្រោងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ដល់ប្រជាពលរដ្ឋ ប្រមូលបញ្ហា តម្រូវការ និងកៀរគរប្រជាពលរដ្ឋឲ្យចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍ មូលដ្ឋានរបស់ខ្លួន។
- សមាជិក គ.ក.ស ចូលរួមយ៉ាងសកម្ម ក្នុងការពិនិត្យមើលការអនុវត្តន៍គម្រោងឃុំ សង្កាត់ និងផ្តល់ព័ត៌មានត្រឡប់ដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ពីភាពមិនប្រក្រតីមួយចំនួនដែលកើតឡើង ជុំវិញការអនុវត្តន៍គម្រោងទាំងនោះ ។
- សមាជិក គ.ក.ស ចូលរួមផងដែរ ជាមួយអាជ្ញាធរមូលដ្ឋាន ក្នុងការសម្របសម្រួលដោះស្រាយបញ្ហានៅក្នុងសហគមន៍ (ឧទាហរណ៍ អំពើហឹង្សាក្នុងគ្រួសារ) ។
- សមាជិក គ.ក.ស ចូលរួមក្នុងការប្រជុំឆ្លុះបញ្ចាំងពីការរីកចំរើនរបស់គម្រោងជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ។
- សមាជិក គ.ក.ស ចូលរួមក្នុងការប្រជុំផ្លាស់ប្តូរយោបល់ បទពិសោធន៍ទាំងក្នុងឃុំ សង្កាត់ និងទាំងអន្តរឃុំ សង្កាត់ ដើម្បីពង្រីកចំណេះដឹងរបស់ខ្លួនឲ្យកាន់តែប្រសើរឡើង ។
- សមាជិក គ.ក.ស ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ក្នុងមូលដ្ឋាន និង ជំរុញលើកទឹកចិត្តឲ្យប្រជាពលរដ្ឋលើកពីបញ្ហា និងតម្រូវការនានា ដែលពួកគាត់ជួបប្រទះ ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីធ្វើការដោះស្រាយ ។
- សមាជិក គ.ក.ស ចូលរួមក្នុងវេទិកាសាធារណៈរវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋ និងលើកសំនួរនានាពាក់ព័ន្ធនឹងថវិកា ផែនការសកម្មភាព ជាពិសេស គឺលទ្ធផលនៃការវិនិយោគរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។
- សមាជិក គ.ក.ស ចូលរួមក្នុងការបិទផ្សាយព័ត៌មានស្តីពីការសម្រេចចិត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងព័ត៌មានអភិវឌ្ឍន៍ក្នុងឃុំនៅលើក្តារព័ត៌មានឃុំ សង្កាត់ និងភូមិ។

# ក- ចូលរួមវគ្គពង្រឹងសមត្ថភាព និងចែករំលែកបទពិសោធន៍




☞ ការពង្រឹងសមត្ថភាព ជាកិច្ចការចាំបាច់ និងមានសារៈសំខាន់ណាស់សម្រាប់ សមាជិក គ.ក.ស ទាំងអស់ព្រោះថា ការសិក្សារៀនសូត្រ នឹងបង្កើនចំណេះដឹង បទពិសោធន៍ និងភាពជឿជាក់ ក្នុងការបំពេញកិច្ចការ ក៏ដូចជាការសម្របសម្រួលដោះស្រាយបញ្ហានានាដែលកើតមានឡើង ។

☞ តាមរយៈវគ្គបណ្តុះបណ្តាលទាំងនេះនឹងបង្កើតបាននូវធនធានមូលដ្ឋានមួយដែលដើរតួនាទីក្នុងនាម ផលប្រយោជន៍របស់សហគមន៍ទាំងមូល ។

# ២ - ប្រមូលព័ត៌មាន បញ្ហា តម្រូវការរបស់អ្នកភូមិ

សមាជិក គ.ក.ស ចុះប្រមូលព័ត៌មាន បញ្ហា និងតម្រូវការជាលក្ខណៈបុគ្គល




សមាជិក គ.ក.ស បានដើរតួនាទីយ៉ាងសកម្មក្នុងការប្រមូលព័ត៌មាន បញ្ហា តម្រូវការនិងសំណូមពរផ្សេងៗ ពីប្រជាពលរដ្ឋមូលដ្ឋានជាលក្ខណៈបុគ្គល ជាក្រុមដែលមានចំរុះជាតិសាសន៍ និង ជាមួយក្រុមយុវជននៅក្នុងសហគមន៍ ។

សមាជិក គ.ក.ស ចុះប្រមូលព័ត៌មាន បញ្ហា និងតម្រូវការជាមួយប្រជាពលរដ្ឋ ខ្មែរឥស្លាម និង បងប្អូនជនជាតិដើមភាគតិច




- សមាជិក គ.ក.ស បានប្រើប្រាស់លទ្ធភាពរបស់ខ្លួនក្នុងការធ្វើឲ្យកើតមាននូវវប្បធម៌មិនរើសអើង ដោយបានចែករំលែករាល់ព័ត៌មានដល់ប្រជាពលរដ្ឋទាំងអស់មិនថាជាតិសាសន៍អ្វីឡើយ។
- តាមរយៈសកម្មភាពស្ម័គ្រចិត្ត និងការលះបង់ពេលវេលារបស់សមាជិក គ.ក.ស បាន ធ្វើឲ្យប្រជាពលរដ្ឋទាំងអស់មិនថាជនជាតិអ្វីទេ បង្ហាញនូវការគោរព និងឲ្យតំលៃខ្ពស់ ដល់សមាជិក គ.ក.ស ដែលបានផ្សព្វផ្សាយរាល់ព័ត៌មាន ក៏ដូចជាផែនការអភិវឌ្ឍន៍ ផ្សេងៗរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។
- បញ្ហា និង តម្រូវការរបស់បងប្អូនខ្មែរឥស្លាម និងជនជាតិដើមភាគតិច ត្រូវបានសមាជិក គ.ក.ស រាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីធ្វើការដោះស្រាយ និងឆ្លើយតប ។

សមាជិក គ.ក.ស ចុះប្រមូលព័ត៌មាន បញ្ហា និងតម្រូវការជាមួយក្រុមយុវជន




- សមាជិក គ.ក.ស បានដើរតួនាទីយ៉ាងសកម្មក្នុងការផ្សព្វផ្សាយព័ត៌មានផ្សេងៗ ដែលទទួលបានពីក្រុមប្រឹក្សាឃុំ សង្កាត់ និងបានផ្តល់នូវគោលគំនិតសំខាន់ៗ ពាក់ព័ន្ធ នឹងបញ្ហាសង្គម ដូចជាបញ្ហាអំពើហឹង្សាក្នុងគ្រួសារ បញ្ហាយុវជន និងបញ្ហាថ្នាំញៀន ផលវិបាកនៃការធ្វើចំណាកស្រុក ផលប៉ះពាល់នៃបរិស្ថាន និងបញ្ហាយេនឌ័រ ជាដើម ។ល។
- សមាជិក គ.ក.ស បានប្រើប្រាស់នូវលទ្ធភាព និងពេលវេលារបស់ខ្លួនធ្វើការជាមួយក្រុមយុវជន និងអប់រំពួកគេអំពីផលប៉ះពាល់អវិជ្ជមាននៃការប្រើប្រាស់គ្រឿងញៀន អំពើហឹង្សា ការប្រព្រឹត្តរបស់ក្មេងទំនើង ល្បែងស៊ីសង និងការធ្វើចំណាកស្រុកទៅកាន់កន្លែងផ្សេងៗទាំងក្នុង និងក្រៅប្រទេស ។

# គ - ចូលរួមកិច្ចប្រជុំរបស់សមាជិកគ.ក.ស




កិច្ចប្រជុំប្រចាំខែ ឬប្រចាំត្រីមាសរបស់ គ.ក.ស មានសារៈសំខាន់ណាស់ព្រោះថា តាមរយៈកិច្ចប្រជុំនេះ សមាជិកគ.ក.ស ធ្វើការរាយការណ៍ពីការអនុវត្តន៍ការងារ ពិភាក្សាបញ្ហាជួបប្រទះ រៀបចំផែនការការងារ បង្កើនភាពស្និតស្នាលជាមួយគ្នា ចែករំលែកបទពិសោធន៍ និងពិភាក្សាគ្នាក្នុងការស្វែងរកដំណោះស្រាយរួមគ្នា ។ កិច្ចប្រជុំនេះ មិនគ្រាន់តែដើម្បីបង្កើនភាពស្និតស្នាល និងចែករំលែកព័ត៌មានទៅវិញទៅមកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាឱកាសមួយដែលសមាជិក គ.ក.ស អាចរៀនសូត្រពីគ្នាទៅវិញទៅមកទៀតផង។

# ឃ - ចូលរួមប្រជុំអាណត្តិរបស់ក្រុមប្រឹក្សាឃុំ






យោងតាមច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ជំពូកទី២ មាត្រាទី ១៣ ចំនុចទី២ ចែងថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មានភារៈកិច្ចធានាឲ្យមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិចឲ្យបានមួយដងក្នុងមួយខែ ហើយក្នុងមាត្រាទី២៣ នៃច្បាប់នេះបានចែងថា ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើជាសាធារណៈ និងមានលក្ខណៈប្រជាធិបតេយ្យ។

យោងទៅលើមាត្រាទាំង២ខាងលើនេះសមាជិក គ.ក.ស បានដើរតួនាទីដ៏សំខាន់ក្នុងការផ្លាស់ប្តូរព័ត៌មានរវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋ ។ ព្រោះថាតាមរយៈវត្តមានរបស់ខ្លួននៅក្នុងកិច្ចប្រជុំនេះ សមាជិក គ.ក.ស បានរាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ពីបញ្ហា និងតម្រូវការរបស់ប្រជាពលរដ្ឋ និងផ្សព្វផ្សាយព័ត៌មាន ដែលទទួលពីឃុំទៅប្រជាពលរដ្ឋវិញតាមរយៈការប្រាស្រ័យទាក់ទងគ្នា ជាលក្ខណៈបុគ្គល និងជាលក្ខណៈក្រុមតូចៗ អំពីការសម្រេចចិត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងកិច្ចប្រជុំអាណត្តិនោះ។



## ៥ - សកម្មភាពចែករំលែកព័ត៌មាន

សកម្មភាពសមាជិក គ.ក.ស ផ្សព្វផ្សាយព័ត៌មានជាលក្ខណៈបុគ្គល




ពូអាន: ក្រុមប្រឹក្សាឃុំ សង្កាត់មានផែនការនឹង
ចុះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីការទប់
ស្កាត់ការប្រើប្រាស់គ្រឿងញៀននៅក្នុង
ភូមិយើងនៅថ្ងៃអាទិត្យក្រោយនេះ ។

សំណាង: ពូ! តើខ្ញុំអាចចូលរួមបានទេ នៅពេល
ក្រុមប្រឹក្សាឃុំ សង្កាត់ចុះមកប្រជុំ
ផ្សព្វផ្សាយហ្នឹង?

ពូអាន: ពិតជាបានសំណាង ! ការផ្សព្វផ្សាយ
នេះ មានសារៈសំខាន់ណាស់ព្រោះ
វាធ្វើឲ្យយើងដឹងពី ផលប៉ះពាល់
នៃការប្រើប្រាស់គ្រឿងញៀន
និងរបៀបទប់ស្កាត់គ្រឿងញៀន។

សំណាង: បើដូច្នេះថ្ងៃអាទិត្យក្រោយ ខ្ញុំពិតជាទៅ
ចូលរួមមិនខានឡើយពូ !

រៀងរាល់ខែក្រុមប្រឹក្សាឃុំ សង្កាត់ តែងរៀបចំការប្រជុំជាសាធារណៈ ហើយតំណាងអង្គការសហគមន៍មូលដ្ឋាន តំណាងមណ្ឌលសុខភាព តំណាងសាលារៀន តំណាង គ.ក.ស តំណាងប៉ុស្តិ៍នគរបាលឃុំ អង្គការ និងសមាគមនានា ត្រូវបានលើកទឹកចិត្ត ឲ្យចូលរួមនៅក្នុងកិច្ចប្រជុំនេះ។

ក្រុមប្រឹក្សាឃុំ សង្កាត់ បានផ្តល់ឱកាសឲ្យអ្នកចូលរួមលើកឡើងនូវរបៀបវារៈ បញ្ហា និង សំណូមពរផ្សេងៗដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ជាពិសេសផ្តល់ឱកាសក្នុងការបញ្ចេញមតិយោបល់ក៏ ដូចជាយោបល់ត្រឡប់ស្តីពីដំណើរការអនុវត្តគម្រោងរបស់ ក្រុមប្រឹក្សាឃុំ សង្កាត់ផងដែរ ។

## សកម្មភាពសមាជិក គ.ក.ស ចុះផ្សព្វផ្សាយព័ត៌មានដល់អ្នកភូមិ




រាល់ព័ត៌មានការសម្រេចចិត្តរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ផែនការវិនិយោគ និងស្ថានភាពថវិការបស់ ឃុំ សង្កាត់ ដែលសមាជិក គ.ក.ស ទទួលបាន ពួកគាត់ធ្វើការផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួនតាមវិធីសាស្ត្រ និងមធ្យោបាយដូចជា:

- ពេលជួបជុំជជែកគ្នាក្រោយពីសំរាកពីការងារដូចជាដកស្ទូង ភ្ជួររាស់ ។ល។
- ពេលជួបជុំគ្នាក្រោយពេលបរិភោគអាហារពេលល្ងាច
- ពេលជួបជុំនៅក្នុងពិធីបុណ្យទានផ្សេងៗ
- ពេលធ្វើដំណើរទៅធ្វើស្រែ ចំការ ឬពេលទៅផ្សារជាដើម ។ ល។

# ៦- តេសមាជិក គ.ក.ស នឹងទទួលចំណេះដឹងអ្វីខ្លះ?

ជាការពិតណាស់សមាជិក គ.ក.ស ទាំងអស់បានទទួលការបណ្តុះបណ្តាល និងការបង្ហាត់បង្ហាញជាប្រចាំពីបុគ្គលិកអង្គការដៃគូថ្នាក់ខេត្តទៅលើប្រធានបទមួយចំនួន ។ សមត្ថភាព និងលទ្ធភាពរបស់សមាជិក គ.ក.ស ទាំងអស់មិនដូចគ្នាទេ ប៉ុន្តែតាម រយៈការចូលរួមយ៉ាងសកម្ម និងកិច្ចខិតខំប្រឹងប្រែងរៀនសូត្រជាប្រចាំរបស់សមាជិក គ.ក.ស ជារួមពួកគាត់ទទួលបាននូវចំណេះដឹងជាច្រើន។

ចំណេះដឹងដែលសមាជិក គ.ក.ស ទទួលបានរួមមាន៖

- ✓ មុខងារ និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ✓ ចំណេះដឹងជាអ្នកដឹកនាំ
- ✓ ចំណេះដឹងក្នុងការសម្របសម្រួលកិច្ចប្រជុំ
- ✓ ជំនាញសរសេររបាយការណ៍
- ✓ ការដេញថ្លៃគម្រោងសេវាកម្ម
- ✓ គោលការណ៍របស់ គណ:កម្មការកៀរគរសហគមន៍
- ✓ ការដោះស្រាយបញ្ហាដោយសន្តិវិធី ឬ ការទប់ស្កាត់ទំនាស់
- ✓ ប្រសិទ្ធិភាពនៃការកៀរគរសហគមន៍
- ✓ ការចរចារ និង ពិគ្រោះយោបល់
- ✓ គោលការណ៍គ្រឹះអភិបាលកិច្ចល្អ
- ✓ ការទំនាក់ទំនងសាធារណៈ
- ✓ ការកសាងភាពជាដៃគូ
- ✓ សិទ្ធរបស់ប្រជាពលរដ្ឋក្នុងការចូលរួមអភិវឌ្ឍន៍មូលដ្ឋាន
- ✓ ចំណេះដឹងក្នុងការតាមដានត្រួតពិនិត្យការអនុវត្តន៍កិច្ចសន្យាគម្រោង

ចំណេះដឹងដែលសមាជិកគ.ក.សបានទទួលដូចរៀបរាប់ខាងលើនេះនឹងជួយបង្កើនសមត្ថភាព និងទំនុកចិត្ត បន្ថែមទៀតដល់ សមាជិក គ.ក.ស ក្នុងការបំពេញតួនាទីរបស់ខ្លួន ឲ្យកាន់តែមានប្រសិទ្ធិភាព។ តាមរយៈសកម្មភាពបណ្ដុះបណ្ដាលនឹងធ្វើឲ្យសមាជិកគ.ក.សទាំងអស់យល់កាន់តែច្បាស់ជាងមុនពីសារៈសំខាន់នៃការរួមចំណែករបស់ខ្លួនក្នុងដំណើរការអភិវឌ្ឍន៍សហគមន៍ជាពិសេសធ្វើឲ្យទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋកាន់តែជិតស្និតថែមទៀត។




សកម្មភាពសិក្សារៀនសូត្រទាំងអស់នេះ មិនគ្រាន់តែដើម្បីបន្តពង្រឹងសមត្ថភាព និងចំណេះដឹងសមាជិក គ.ក.ស ប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងបានលើកទឹកចិត្តសមាជិក គ.ក.ស ឲ្យកាន់តែសកម្មថែមទៀតក្នុងការកៀរគរ និងបន្តចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍សហគមន៍របស់ខ្លួនឲ្យមានភាពរីកចំរើន។ ការរួមវិភាគទានទាំងនេះ នឹងជួយធ្វើឲ្យមានការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អនៅសហគមន៍ កាន់តែមានភាពសុក្រិតពីមួយថ្ងៃទៅមួយថ្ងៃ។

## តើនរណាខ្លះដែលអាចក្លាយជាសមាជិក គ.ក.ស



## តើសមាជិកគ.ក.សនឹងទទួលបានអត្ថប្រយោជន៍អ្វីខ្លះ?



## ចូលរួមវគ្គពង្រឹងសមត្ថភាពនិងចែករំលែកបទពិសោធន៍




## ប្រមូលព័ត៌មាន បញ្ហា តម្រូវការរបស់អ្នកភូមិ



## សមាជិក គ.ក.ស ចុះប្រមូលព័ត៌មាន បញ្ហា និងតម្រូវការ ជាមួយប្រជាពលរដ្ឋ ខ្មែរឥស្លាម និង បងប្អូនជនជាតិដើម



## សមាជិក គ.ក.ស ចុះប្រមូលព័ត៌មាន បញ្ហា និងតម្រូវការជាមួយក្រុមយុវជន



## ចូលរួមកិច្ចប្រជុំរបស់សមាជិកគ.ក.ស



## ចូលរួមប្រជុំអាណត្តិរបស់ក្រុមប្រឹក្សាឃុំ



## សកម្មភាពសមាជិក គ.ក.ស ផ្សព្វផ្សាយព័ត៌មានជាលក្ខណៈបុគ្គល



## សកម្មភាពសមាជិក គ.ក.ស ចុះផ្សព្វផ្សាយព័ត៌មានដល់អ្នកភូមិ




## តើសមាជិក គ.ក.ស នឹងទទួលចំណេះដឹងអ្វីខ្លះ?



# អភិបាលកិច្ចល្អ

